ក្រសួងមហាផ្ទៃ

ស្ថានទូតអូស្ត្រាលី
ភ្នំពេញ

# សេចក្តីប្រកាសព័ត៌មានរួម

②⓪⑧⑩

## ប្រទេសអូស្ត្រាលីផ្តល់ជំនួយលើការសាងសង់អាគារនគរបាលយុត្តិធម៌ នៅខេត្តបាត់ដំបង អោយកាន់តែល្អប្រសើរ

ឯកឧត្តម **ញ៉ាំ សុខា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និង លោកជំទាវ **ម៉ាហ្គារេត អាដាមសុន** ឯកអគ្គរាជទូត អូស្ត្រាលីប្រចាំកម្ពុជា នឹងសម្ពោធបើកអោយប្រើប្រាស់នូវអគារនគរបាលយុត្តិធម៌ថ្មីនៅក្នុងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០ ។

អគារថ្មីនេះ គឺជាផ្នែកមួយនៃការគាំទ្ររបស់រដ្ឋាភិបាលអូស្ត្រាលី សំរាប់ធ្វើអោយល្អប្រសើរផ្នែកហេដ្ឋារចនាសម្ព័ន្ធ តាមរយៈគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា (CCJAP) ។ រដ្ឋាភិបាលអូស្ត្រាលីបានផ្តល់ថវិកាចំនួន ៤លានដុល្លាអូស្ត្រាលី តាមរយៈគម្រោង CCJAP សំរាប់សាងសង់អគារនគរបាល តុលាការ និង ពន្ធនាគារ នៅក្នុងខេត្តចំនួន០៥ (រួមមាន ខេត្តបាត់ដំបង ព្រៃវែង បន្ទាយមានជ័យ កំពង់ធំ និងខេត្តកំពង់ចាម) អោយមានលក្ខណៈកាន់តែល្អប្រសើរ ។

ថ្លែងក្នុងពិធីបើកសម្ពោធ លោកជំទាវ **ម៉ាហ្គារេត អាដាមសុន** មានប្រសាសន៍ថា "អគារថ្មីនេះនឹងផ្តល់លក្ខខ័ណ្ឌការងារអោយកាន់តែល្អប្រសើរសម្រាប់មន្ត្រីនគរបាលអនុវត្តការងារកាន់តែមានប្រសិទ្ធិភាព ។ អគារនេះក៏ផ្តល់លក្ខណៈងាយស្រួល សម្រាប់ជនជាប់ចោទ ជនរងគ្រោះ និង សំរាប់ប្រជាពលរដ្ឋដែលសហការជាមួយនគរបាលដើម្បីរាយការណ៍ និង កាត់បន្ថយបទល្មើស" ។

ឯកឧត្តម **ញ៉ាំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃមានប្រសាសន៍ថា "ហេដ្ឋារចនាសម្ព័ន្ធនេះគឺជាឧទាហរណ៍មួយយ៉ាងល្អបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលទាំងពីរ ក្នុងការគាំទ្រគោលនយោបាយកំណែទម្រង់នៅក្នុងប្រទេសកម្ពុជា ។ ឥឡូវនេះ យើងមានមន្ត្រីនគរបាលដែលមានសមត្ថភាព រួមជាមួយហេដ្ឋារចនាសម្ព័ន្ធថ្មីនេះ ខ្ញុំជឿជាក់ថា មន្ត្រីនគរបាលរបស់យើងនឹងអាចអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនអោយ

កាន់តែមានប្រសិទ្ធិភាព និងប្រកបដោយវិជ្ជាជីវៈ ដើម្បីធានាអោយបាននូវសន្តិសុខ សុវត្ថិភាពជូនសហគមន៍ ហើយព្រមទាំងទទួលបាននូវការទុកចិត្ត និង ភាពជឿជាក់កាន់តែខ្លាំងពីសហគមន៍ " ។

លោកឧត្តមសេនីយ៍ **ស ថេត** ស្នងការនគរបាលខេត្តបាត់ដំបង មានប្រសាសន៍ថា "អគារនេះនឹងជួយផ្តល់លទ្ធភាពអោយស្នងការដ្ឋាននគរបាលខេត្ត ផ្សារភ្ជាប់សកម្មភាពការងារសំខាន់ៗទៅនឹងទិសដៅជាយុទ្ធសាស្ត្ររបស់អគ្គស្នងការនគរបាលជាតិ និង ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរបស់នគរបាលខេត្តដើម្បី ពង្រីកកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសវេជ្ជសាស្ត្រ និង ការអភិវឌ្ឍន៍នានាដែលទាក់ទងនឹងចំណុចសំខាន់ៗនៃការធ្វើសម្ភាសន៍ និង កម្មវិធីបណ្តុះបណ្តាលដើម្បីគាំទ្រដល់ការងារស៊ើបអង្កេតបទល្មើស បំពារបំពានផ្លូវភេទ ជាពិសេស ទៅលើស្ត្រី និងកុមារ " ។

រដ្ឋាភិបាលអូស្ត្រាលីបានគាំទ្រកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩៧ ។ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ (ចាប់ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១២) អនុវត្តការងារជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និង សហគមន៍ដើម្បីលើកកំពស់ការងារផ្នែកពន្ធនាគារ នគរបាល តុលាការ និង ការងារទប់ស្កាត់បទល្មើស និង រក្សាសុវត្ថិភាពសហគមន៍ នៅក្នុងខេត្តចំនួន ០៦ ។

**ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ**

**អាន្ទី ផាតែល** ស្ថានទូតអូស្ត្រាលី តាមរយៈទូរស័ព្ទ ០២៣ ២១៣ ៤៧០

**ស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ**

ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០